# វិធានតុលាការ សម្រាប់ការជំនុំជម្រះក្តីបញ្ហាបរិស្ថាន



ក្រុមប្រឹក្សាតុលាការឧទ្ធរណ៍ផ្នែកបរិស្ថាន
ទីភ្នាក់ងារការពារបរិស្ថានសហរដ្ឋអាមេរិច
សីហា ២០១៧

# ការបង្ហាញអំពីវិធានរបស់តុលាការ

ផ្នែកទី I

តួនាទីតុលាការបរិស្ថាននិងគោលការណ៍ដែលជាមគ្គុទេសក៏សម្រាប់ការជំនុំជម្រះក្តីបញ្ហាបរិស្ថាននៅក្នុងសហរដ្ឋអាមេរិច

ផ្នែកទី II.

វិធានតុលាការ

ផ្នែកទី III.

សកម្មភាពជាក្រុម

# តួនាទីរបស់តុលាការបរិស្ថាននៅអាមេរិច

- តុលាការនាំមកនូវគណនេយ្យភាពនិងភាពច្បាស់លាស់ដល់ប្រព័ន្ធ
- តុលាការជួយលើកកម្ពស់នីតិរដ្ឋ
- តុលាការជួយធានាថា វិធាននិងបទប្បញ្ញត្តិនានាត្រូវបានពង្រឹងអនុវត្ត
- ចៅក្រមដែលមានឯកទេស ផ្តល់ជំនាញនៅក្នុងវិស័យបច្ចេកទេសស្មុគ្រស្មាញ
- តុលាការរដ្ឋបាលឯកទេស អាចដំណើរការលឿនជាង និងចំណាយតិចជាងតុលាការសហព័ន្ធដែលមានយុត្តាធិការទូទៅ



# គោលការណ៍បួនដែលណែនាំផ្លូវសម្រាប់ការជំនុំជម្រះក្នុងសហរដ្ឋអាមេរិច



1. ឯករាជ្យភាព
2. តម្លាភាព
3. សវនាការពេលពេញនិងយុត្តិធម៌
4. សង្គតិភាពនៃការជំនុំជម្រះ

# 1. ឯករាជ្យភាព

- ឯករាជ្យភាពតុលាការ មានន័យថាជាសេរីភាពមិនទទួលរងឥទ្ធិពលពីខាងក្រៅ៖
  - សេរីភាពរួចផុតពីឥទ្ធិពលនយោបាយ
  - សេរីភាពរួចផុតពីឥទ្ធិពលទឹកប្រាក់
  - សេរីភាពរួចផុតពីឥទ្ធិពលនយោបាយផ្ទាល់ខ្លួន



# ឯករាជ្យភាព (បន្ត...)

- ចៅក្រមត្រូវតែជាអ្នកសម្រេចចិត្តដែលមិនលម្អៀង
  - ការស្បថចូលកាន់តំណែងរបស់តុលាការ – 28 U.S.C. § 453
  - មិនមានការពាក់ព័ន្ធពីមុនមក ក្នុងការស៊ើបអង្កេតឬចោទប្រកាន់នៅក្នុងសំណុំរឿង
  - អាចត្រូវគេដកហូតសិទ្ធិ ដោយសារការពាក់ព័ន្ធផ្នែកហិរញ្ញវត្ថុពីក្នុងលទ្ធផលនៃសំណុំរឿង



# 2. តម្លាភាព

- ការសម្រេចចិត្តប្រកបដោយតម្លាភាព
  - វិធាន នីតិវិធី កាតព្វកិច្ច និងស្តង់ដារ ច្បាស់លាស់
  - ការតម្រូវឲ្យមានកំណត់ត្រាជាលក្ខខណ្ឌអក្សរ ដាក់ឲ្យសាធារណជនរកបាន
  - រាល់សវនាការទាំងអស់ត្រូវបើកចំហជាសាធារណៈ
  - មិនមានការប្រាស្រ័យទាក់ទងតែជាមួយភាគីម្ខាង ដោយរាប់ទាំងបុគ្គលិក EPA ណាមួយទេ គឺផ្អែកលើអង្គសេចក្តីនៃសំណុំរឿង
  - ការសម្រេចចិត្ត ដីកា និងសារណាទាំងឡាយ អាចរកបានជាសាធារណៈតាមប្រព័ន្ធអ៊ីនធឺណែត (www.epa.gov/eab)

# 3. សវនាការពេលពេញនិងយុត្តិធម៌



- **សិទ្ធិទទួលបានសវនាការ៖** ភាគីទាំងអស់មានសិទ្ធិក្នុងការបង្ហាញករណីល្អបំផុតរបស់ខ្លួន ទៅដល់អ្នកធ្វើការសម្រេចចិត្ត
- **នៅពេលជំនុំជម្រះ៖** ភាគីអាចបង្ហាញសាក្សីនិងភស្តុតាងជាឯកសារ និងឆ្លើយតបទៅកាន់ភស្តុតាងដែលភាគីម្ខាងទៀតបង្ហាញ
  - បណ្តុំភស្តុតាង បង្កើតជាមូលដ្ឋាននៃការសម្រេចរបស់ចៅក្រម
  - ត្រូវតែជា "ភស្តុតាងដែលអាចជឿជាក់បាន អាចបញ្ជាក់បាន និងជាសារធាតុ" (ច្បាប់ស្តីពីនីតិវិធីរដ្ឋបាល (APA §556d))
- **ការប្តឹងឧទ្ធរណ៍៖** ការសម្រេចចិត្ត ផ្អែកទៅលើកំណត់ត្រារដ្ឋបាលនៃសេចក្តីសម្រេចដែលត្រូវបានប្តឹងឧទ្ធរណ៍។ ភាគីទាំងអស់ មានឱកាសពេញលេញក្នុងការតស៊ូមតិទៅលើជំហររបស់ខ្លួន តាមរយៈការដាក់សារណា ការបង្ហាញទឡ្ហីករណ៍ផ្ទាល់មាត់ ប្រសិនបើសាលាក្តីកំណត់ថាវាមានប្រយោជន៍ និងឈានទៅដល់ការពិចារណាឡើងវិញសម្រាប់ការសម្រេចជាស្ថាពរ។

# 4. សង្គតិភាពនៃការជំនុំជម្រះ

- ការសម្រេចចិត្តរបស់សាលាឧទ្ធរណ៍ បង្កើតបានជាសកម្មភាពទីភ្នាក់ងារជាស្ថាពរទៅលើបញ្ហាជាក់លាក់ណាមួយ និងដើរតួនាទីជាករណីយុត្តិសាស្ត្រសម្រាប់សំណុំរឿងក្នុងពេលអនាគត
- ការបោះពុម្ពផ្សាយសេចក្តីសម្រេចសាលាឧទ្ធរណ៍ តាមរយៈប្រព័ន្ធអ៊ីនធឺណែត ហើយឯកសារដែលត្រូវបានបោះពុម្ពផ្សាយ ផ្តល់ឲ្យមានការទទួលបានសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ទៅលើប្រធានបទណាមួយ និងលើកកម្ពស់ភាពទាយទុកមុន ទៅលើផ្នែកណាមួយនៃឧស្សាហកម្មដែលមានច្បាប់បញ្ញត្តិ និងពលរដ្ឋដែលមានចំណាប់អារម្មណ៍
- វិធានរបស់តុលាការក្នុងការធ្វើឲ្យគោលការណ៍ទាំងនេះមានប្រសិទ្ធភាព

# វិធានតុលាការ



## គោលបំណងនៃវិធានតុលាការ

## យន្តការសម្រាប់ការកំណត់វិធានតុលាការ

- ដោយវិធានតុលាការ
- ដោយបទបញ្ញត្តិ
- ដោយដីកាអំពីសិទ្ធិប្តឹង
- ការណែនាំបង្ហាញផ្លូវ

## មាតិកាដែលអាចដាក់បាន សម្រាប់វិធានតុលាការ

- អំណាចរបស់តុលាការ
- សុចរិតភាពនៃដំណើរការ
- សិទ្ធិប្តឹង
- បន្ទុកនិងការសន្មត
- វិធាននីតិវិធី
- ដំណោះស្រាយ



# គោលបំណងនៃវិធានតុលាការ



## ឧទាហរណ៍ពីប្រទេសហ្វីលីពីន

- វិធានតុលាការប្រទេសហ្វីលីពីន ផ្នែកទី៣ គោលបំណង៖
- ការពារនិងជំរុញសិទ្ធិរបស់មនុស្សតាមរដ្ឋធម្មនុញ្ញ ក្នុងការទទួលបាននូវប្រព័ន្ធអេកូឡូស៊ីមួយដែលមានតុល្យភាពនិងសុខភាពល្អ
- ផ្តល់នូវនីតិវិធីមួយដែលសាមញ្ញ លឿន និងមិនចំណាយច្រើន សម្រាប់ការពង្រឹងការអនុវត្តទៅលើសិទ្ធិនិងការកិច្ចផ្នែកបរិស្ថាន ដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ច្បាប់ដែលមានជាធរមាន វិធាន និងបទប្បញ្ញត្តិ ព្រមទាំងកិច្ចព្រមព្រៀងអន្តរជាតិ
- ណែនាំនិងអនុម័តការច្នៃប្រឌិតថ្មីៗ និងការអនុវត្តល្អបំផុត ក្នុងការធានាឲ្យមានការពង្រឹងការអនុវត្តប្រកបដោយប្រសិទ្ធភាពទៅលើដំណោះស្រាយនិងសំណង សម្រាប់ការបំពានច្បាប់បរិស្ថាន និង
- ផ្តល់លទ្ធភាពឲ្យតុលាការតាមដាន និងដាក់ឲ្យចំនួវការអនុលោមតាមដីកានិងសេចក្តីវិនិច្ឆ័យនៅក្នុងសំណុំរឿងបរិស្ថាន។

# វិធីសាស្ត្រសម្រាប់ការកំណត់វិធានតុលាការ



- ដោយវិធានតុលាការ
- ដោយបទប្បញ្ញត្តិ
- ដោយដីកាអំពីសិទ្ធិប្តឹង
- ការណែនាំបង្ហាញផ្លូវ

# ដោយបទប្បញ្ញត្តិ



- នៅក្នុងសហរដ្ឋអាមេរិច ក្រមនៃបទប្បញ្ញត្តិរបស់សហព័ន្ធ បង្ហាញអំពីវិធានដែលអនុវត្តចំពោះ ក្រុមប្រឹក្សាឧទ្ធរណ៍បរិស្ថាន៖
    - 40 CFR ផ្នែកទី 22: គ្រប់គ្រងទៅលើនីតិវិធីសម្រាប់សវនាការ និងការប្តឹងឧទ្ធរណ៍ ទៅលើសំណុំរឿងពង្រឹងការអនុវត្តផ្នែកបរិស្ថានតាមបែបរដ្ឋបាល
    - 40 C.F.R. ផ្នែកទី 124: គ្រប់គ្រងទៅលើនីតិវិធីដែលអនុវត្តចំណោះការសម្រេចផ្តល់លិខិតអនុញ្ញាត និងការប្តឹងឧទ្ធរណ៍ចេញពីការសម្រេចផ្តល់លិខិតអនុញ្ញាតនោះ
    - បណ្តុំបទប្បញ្ញត្តិទាំងពីរនេះ អាចរកបាននៅលើគេហទំព័ររបស់ EAB

    www.epa.gov/eab/regulations governing appeals
- តុលាការសហរដ្ឋអាមេរិច បានប្រកាសដាក់ឲ្យប្រើប្រាស់វិធាននីតិវិធីខ្លួនឯង
    - វិធាននីតិវិធីរដ្ឋប្បវេណីរបស់សហព័ន្ធ
    - វិធាននីតិវិធីប្តឹងឧទ្ធរណ៍របស់សហព័ន្ធ
    - វិធានភស្តុតាងរបស់សហព័ន្ធ

# ដោយដីកាអំពីសិទ្ធិប្តឹង

- សាលាក្តីសហរដ្ឋអាមេរិច អាចចេញដីកាអំពីសិទ្ធិប្តឹង ដែលគ្រប់គ្រងទៅលើនីតិវិធីរបស់ខ្លួន ដែលអនុវត្តទៅលើជនទាំងឡាយដែលនៅចំពោះសាលាក្តី
- ឧទាហរណ៍ បានចេញដីកាអំពីសិទ្ធិប្តឹងជាច្រើន ដែលអាចរកបាននៅតាមអ៊ីនធឺណែត ដើម្បីណែនាំបង្ហាញផ្លូវដល់អ្នកអនុវត្ត ដោយរួមមានទាំង៖
  - ដីការអំពីការដាក់ពាក្យតាមទម្រង់អេឡិចត្រូនិច
  - នីតិវិធីដាក់លាក់សម្រាប់ប្រភេទនៃសំណុំរឿងចេញលិខិតអនុញ្ញាតិទាក់ទងនឹងខ្យល់

(www.epa.gov/eab/standing_orders)

# ដីកាអំពីសិទ្ធិប្ដឹង (បន្ត)



ភាសាជាគម្រូមួយចំនួន៖

(ចេញពីដីកាអំពីសិទ្ធិប្ដឹងរបស់ EAB ក្នុងការគ្រប់គ្រងទៅលើការដាក់ញត្តិ ដើម្បីស្នើឲ្យមានការពិនិត្យឡើងវិញទៅលើលិខិតអនុញ្ញាតិពិនិត្យឡើងវិញអំពីប្រភពថ្មីនៃច្បាប់ស្ដីពីខ្យល់ស្អាត, ថ្ងៃ ២៧ ខែមិនា ឆ្នាំ២០១៣)

- "ដើម្បីសម្រួលឲ្យមានដំណោះស្រាយឆាប់រហ័សអំពីការប្ដឹងឧទ្ធរណ៍សុំឲ្យពិនិត្យឡើងវិញទៅលើប្រភពថ្មីនៃច្បាប់ស្ដីពីខ្យល់ស្អាត ខណៈដែលស្របគ្នានោះ ត្រូវផ្ដល់ការពិចារណាឲ្យបានយុត្តិធម៌ទៅលើបញ្ហានានាដែលបានលើកឡើងនៅក្នុងបញ្ហាណាមួយនោះ ក្រុមប្រឹក្សាអនុម័តនីតិវិធីដូចខាងក្រោម" ដីកាកែសម្រួល

- ក្រុមប្រឹក្សាភិបាល នឹងប្រើប្រាស់ការរៀបចំពេលវេលា និងការជួបជុំអំពីឋានៈទាំងនោះ ដើម្បីពន្លឿនការដាក់សារណា ការបង្រួមបញ្ហានៅដំណាក់កាលឧទ្ធរណ៍ និងដំណោះស្រាយសម្រាប់សំណុំរឿងទាំងនោះ។ ភាគីអាចស្នើសុំក្រុមប្រឹក្សាឲ្យដាក់ពេលវេលាសម្រាប់ការជួបជុំបែបនេះដើម្បីពន្លឿនដំណោះស្រាយសម្រាប់សំណុំរឿង

- "នៅទីដែលភាគីនានា ជឿថាការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ អាចជាជំនួយការមួយក្នុងការដោះស្រាយបញ្ហាជម្លោះបាន តាមរយៈការធ្វើញត្តិរួមគ្នានោះ ពួកគេអាចស្នើសុំការចូលរួមនៅក្នុងកម្មវិធីដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការរបស់ក្រុមប្រឹក្សាបាន។

# ការណែនាំបង្ហាញផ្លូវ



- ក្រុមប្រឹក្សាបានដាក់ចេញនូវឯកសារជាច្រើននៅលើអ៊ីនធឺណែត ដើម្បីផ្តល់ការណែនាំបង្ហាញផ្លូវដល់អ្នកអនុវត្តនិងសាធារណជន
  - សៀវភៅណែនាំអនុវត្ត
  - សៀវភៅណែនាំបង្ហាញផ្លូវសម្រាប់ពលរដ្ឋ
  - www.epa.gov/eab/guidance_documents

# មាតិកាដែលអាចដាក់បានសម្រាប់វិធានតុលាការ

- អំណាចរបស់តុលាការ
- សុចរិតភាពនៃដំណើរការ
- សិទ្ធិប្ដឹង
- បន្ទុកនិងការសន្និដ្ឋាន
- វិធាននីតិវិធី
- ដំណោះស្រាយ

# វិធានទាក់ទងនឹងអំណាចរបស់តុលាការ



ឧទាហរណ៍ចេញពីបទប្បញ្ញត្តិរបស់ EPA

អំណាចមួយចំនួនរបស់ប្រធានអង្គជំនុំជម្រះដូចមានរៀបរាប់នៅក្នុង 40 C.F.R. ផ្នែក 22.4:

1. រៀបចំសវនាការរដ្ឋបាល
2. សម្រេចទៅលើញត្តិ និងចេញដីកា
3. ត្រួតពិនិត្យទៅលើការស្បថ និងលិខិតថ្លែងសច្ចា
4. សាកសួរសាក្សីនិងទទួលភស្តុតាងឯកសារនិងភស្តុតាងផ្សេងៗទៀត
5. បញ្ជាឲ្យភាគីណាមួយផ្តល់សក្ខីកម្ម ឯកសារ ឬភស្តុតាងផ្សេងទៀត
6. ទទួលយកភស្តុតាង
7. បើកសវនាការនិងសម្រេចទៅលើសំណួរអំពីអង្គហេតុ អង្គច្បាប់ និងឆន្ទានុសិទ្ធិ
8. តម្រូវឲ្យភាគីទាំងទ្បាយចូលរួមការជួបជុំដើម្បីដោះស្រាយឬធ្វើឲ្យបញ្ហាមានភាពសាមញ្ញ ឬពន្លឿនដំណើរការនីតិវិធី
9. ចេញដីកាកោះហៅសាក្សី

# វិធានទាក់ទងនឹងអំណាចរបស់តុលាការ (បន្ត)



អំណាចរបស់ EAB កំណត់ដោយបទប្បញ្ញត្តិ (40 CFR 22.4):

- ក្រុមប្រឹក្សាតុលាការឧទ្ធរណ៍ផ្នែកបរិស្ថាន - វិធានអំពីការប្តឹងឧទ្ធរណ៍ទៅលើសេចក្តីសម្រេចដែលចេញដោយប្រធានអង្គជំនុំជម្រះ
- ក្នុងការអនុវត្តភារកិច្ចនិងការទទួលខុសត្រូវ ក្រុមប្រឹក្សាតុលាការឧទ្ធរណ៍ផ្នែកបរិស្ថាន  អាចធ្វើរាល់ទង្វើនិងចាត់រាល់វិធានការ តាមការចាំបាច់ដើម្បីធានាឲ្យមានការជំនុំជម្រះក្តីមួយប្រកបដោយប្រសិទ្ធផល យុត្តិធម៌ និងមិនលម្អៀង ទៅលើបញ្ហានានាដែលបានកើតនៅក្នុងដំណើរការនីតិវិធី

# វិធានទាក់ទងនឹងសុចរិតភាពនៃដំណើរការ



ឧទាហរណ៍នៃវិធានដើម្បីប្រយោជន៍ភាគីតែម្ខាង

ច្បាប់សហរដ្ឋអាមេរិច (ច្បាប់នីតិវិធីរដ្ឋបាល) :

- គ្មាននរណាម្នាក់នៅក្រៅទីភ្នាក់ងារ អាចប្រាស្រ័យទាក់ទងជាមួយនឹងនរណាម្នាក់នៅក្នុងទីភ្នាក់ងារ (ដោយរួមទាំងចៅក្រម) ដែលគេរំពឹងថានឹងមានការពាក់ព័ន្ធក្នុងដំណើរការធ្វើការសម្រេចចិត្តនោះទេ
- ប្រសិនបើនរណាម្នាក់នៅក្នុងទីភ្នាក់ងារ ទទួលបានការប្រាស្រ័យទាក់ទងដែលបំពានលើវិធានដើម្បីប្រយោជន៍ភាគីតែម្ខាង ទីភ្នាក់ងារ (រួមទាំងចៅក្រម) ផង អាចទាត់ចោល បដិសេធ ឬមិនប៉ះពាល់ផលប្រយោជន៍ណាមួយ ឬអះអាងថាដោះស្រាយការបំពាននោះហើយ ដើម្បីផលប្រយោជន៍យុត្តិធម៌

បទប្បញ្ញត្តិ EPA:

- វាអាចមានការប្រាស្រ័យទាក់ទងដែលមិនមែនដើម្បីផលប្រយោជន៍របស់ភាគីតែម្ខាងអំពីសំណុំរឿងរវាងអ្នកធ្វើការសម្រេចចិត្ត(ឬបុគ្គលដែលទំនងជានឹងផ្តល់ដំបូន្មាន ដល់អ្នកធ្វើការសម្រេចចិត្ត) បុគ្គលដែលមានប្រយោជន៍ណាម្នាក់នៅក្រៅ ទីភ្នាក់ងារ ឬជាមួយបុគ្គលិកទីភ្នាក់ងារណាមួយ ដែលបានបំពេញមុខងារចោទប្រកាន់ឬស៊ើបអង្កេតនៅក្នុងដំណើរការនីតិវិធីនេះ ឬដំណើរការនីតិវិធីមានការពាក់ព័ន្ធដោយអង្គហេតុ ឬមានការតំណាងណាមួយសម្រាប់បុគ្គលនោះ។

# សិទ្ធិប្តឹង

ឧទាហរណ៍ពីប្រទេសថៃ

អនុសាសន៍របស់ប្រធានតុលាការកំពូលៈ

*សិទ្ធិក្នុងការប្តឹងនៅនៅក្នុងរឿងក្តី បរិស្ថាន ត្រូវកំណត់ឡើងដោយមានការពិចារណាអំពីសិទ្ធិរបស់បុគ្គលក្នុងការទទួលបានផលប្រយោជន៍ពីធនធានធម្មជាតិនិងជីវសាស្ត្រចម្រុះ ក៏ដូចជាសិទ្ធិក្នុងការរស់នៅក្នុងជីវិតធម្មតាប្រកបដោយនិរន្តរភាព នៅក្នុងបរិស្ថានមួយដែលមានសេរីភាពរួចផុតពីការបង្កការខូចខាតដល់សុខភាព សុមាលភាព ឬ គុណភាពជីវិតដូចដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញប្រទេសថៃ*

## វិធានទាក់ទងនឹងបន្ទុកភស្តុតាង

- បទប្បញ្ញត្តិរបស់ EPA បានដាក់បន្ទុកភស្តុតាងក្នុងការបង្ហាញ និងពន្យល់អូសទាញ ទៅលើទីភ្នាក់ងារ
- ទីភ្នាក់ងារ ត្រូវតែបង្ហាញបញ្ជាក់ថា ការរំលោភបំពានបានកើតឡើងដូចការចោទ និងថាការស្នើរកជំនួយដំណោះស្រាយ គឺជាការសមស្រប
- អ្នកបំពានដែលត្រូវបានគេចោទ មានបន្ទុកក្នុងការបង្ហាញនិងពន្យល់អូសទាញ សម្រាប់ការការពារក្តី
- ប្រធានអង្គជំនុំជម្រះ ត្រូវសម្រេចទៅលើបញ្ហានិមួយៗដែលមានភាពប្រទាញប្រទង់ តាមរយៈឧត្តមានុភាពនៃភស្តុតាង។

# វិធានទាក់ទងនឹងការសន្មត



**ឧទាហរណ៍ពី ញូវយ៉ក**

ច្បាប់អភិរក្សបរិស្ថាន រដ្ឋញូវយ៉ក 71-2719

- ការកាន់កាប់សំណល់មានគ្រោះថ្នាក់ឬសារធាតុដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាពសាធារណៈ សុវត្ថិភាពសាធារណៈ ឬបរិស្ថាន ដែលមានចំនួន ១៥០០ ហ្គាឡុង ឬ១៥០០០ផោន **គឺជាភស្តុតាងសន្មតថាបានដឹង** គឺបុគ្គលដែលកាន់កាប់សំណង់ឬសារធាតុនោះ ត្រូវបានសន្មតថាបានដឹងថា សម្ភារៈទាំងនោះ ជាសំណល់ឬសារធាតុណាមួយ ដែលមានគ្រោះថ្នាក់ដល់ សុខភាពសាធារណៈ សុវត្ថិភាពសាធារណៈ ឬបរិស្ថាន

# វិធាននីតិវិធី



- ការផុតកំណត់នៃការដាក់បណ្តឹង
- នីតិវិធីសម្រាប់ដាក់ពាក្យ (កន្លែងណា និង ដោយរបៀបណា)
- អ្នកណាអាចដាក់បាន?
- ខ្លឹមសារតម្រូវ
- ការកំណត់ចំនួនទំព័រ
- សំណូមពរលើកទឡ្ហីករណ៍ផ្ទាល់មាត់
- ការអនុវត្តទៅលើញត្តិ
- វិធានទាក់ទងនឹងភស្តុតាង
- វិធានទាក់ទងនឹងការសម្រេច

# វិធានទាក់ទងនឹងភស្តុតាង



- ភាពអាចទទួលយកបាន
  - នៅក្នុងសហរដ្ឋអាមេរិច ភស្តុតាង អាចទទួលយកបាន នៅពេលដែលវាជាប់ទាក់ទង ជឿជាក់បាន អាចបញ្ជាក់បាន និងជាសម្ភារៈ
  - ឧទាហរណ៍ បទប្បញ្ញត្តិ EPA ស្តីពីភស្តុតាង ចែងថា៖
    *ប្រធានអង្គជំនុំជម្រះ ត្រូវទទួលយកភស្តុតាងទាំងអស់ ដែលជាប់ទាក់ទង ជាសម្ភារៈ មិនស្ទួនហួសហេតុពេក ជឿជាក់បាន ដែលអាចបញ្ជាក់បានទោះតិចតួចក៏ដោយ*

- សាក្សី
  - សាក្សីត្រូវបានសាក្សីផ្ទាល់មាត់ ដោយមានការស្បថ ឬដោយប្រធានអង្គជំនុំជម្រះ
  - ភាគីទាំងឡាយ មានសិទ្ធិចោទសួរទៅលើសាក្សីណាមួយបាន
  - ប្រធានអង្គជំនុំជម្រះ អាចទទួលយកលិខិតថ្លែងសច្ចារបស់សាក្សី ដែលមិនអាចមកបាន
  - សាក្សីជាអ្នកជំនាញ
  - សាក្សីអាចមានគុណសម្បត្តិគ្រប់គ្រាន់ តាមរយៈចំណេះដឹង ជំនាញ បទពិសោធន៍ ឬការអប់រំ អាំចផ្តល់សក្ខីកម្មក្នុងទម្រង់ជាទស្សនៈយោបល់

# វិធានទាក់ទងនឹងភស្តុតាង (បន្ត)



ឧទាហរណ៍ពី តុលាការកំពូលប្រទេសហ្វីលីពីន

## ភស្តុតាងជាឯកសារ - វិធាន ២១

- រូបថត វីដេអូ និងភស្តុតាងស្រដៀងគ្នានេះ អំពីព្រឹត្តិការណ៍ ទង្វើសកម្មភាព កិច្ចការជំនួញសត្វព្រៃ ផលិតផលធ្វើពីសត្វព្រៃ ឬភស្តុតាងរាយរង ផលិតផលពីព្រៃ ឬធនធានរ៉ែ ដែលជាកម្មវត្ថុនៃសំណុំរឿង ត្រូវតែអាចទទួលយកបាន នៅពេលបញ្ជាក់អំពីយថាភូតដោយបុគ្គលដែលយករបស់មកដូចគ្នា ដោយបុគ្គលផ្សេងទៀតដែលមានវត្តមាននៅពេលយកភស្តុតាងនោះ ឬដោយបុគ្គលមានសមត្ថកិច្ចផ្សេងទៀត ដេលផ្តល់សក្ខីកម្មអំពីភាពត្រឹមត្រូវនៅពេលនោះ

- ការបញ្ចូលទៅក្នុងកំណត់ត្រាផ្លូវការ ដែលធ្វើឡើងក្នុងពេលបំពេញភារកិច្ចដោយមន្ត្រីសាធារណៈនៃប្រទេសហ្វីលីពីន ឬដោយបុគ្គលដែលបំពេញភារកិច្ចត្រូវបានច្បាប់បង្គាប់ជាពិសេស គឺជាភស្តុតាងឃើញដោយផ្ទាល់ទៅលើអង្គហេតុដែលបានលើកឡើងនៅកន្លែងនោះ

# វិធានទាក់ទងនឹងភស្តុតាង (បន្ត)



**ឧទាហរណ៍ពី តុលាការកំពូលប្រទេសចិន**

ទាក់ទងនឹងទស្សនៈយោបល់របស់អ្នកជំនាញ និងការអនុវត្តច្បាប់ក្នុងបណ្តឹងវិវាទផលប្រយោជន៍រដ្ឋប្បវេណីសាធារណៈទាក់ទងនឹងបរិស្ថាន (2015)

- នៅទីដែលភាគីដាក់ពាក្យសុំឲ្យមានអ្នកជំនាញដែលមានចំណេះដឹងពិសេស ដើម្បីផ្តល់សក្ខីកម្មនៅក្នុងការធ្វើសវនាការ ដើម្បីផ្តល់យោបល់ទៅលើទស្សនៈយោបល់ជាការវាយតម្លៃ ឬ ផ្តល់ទស្សនៈយោបល់ទៅលើបញ្ហាពិសេស ដូចជា ហេតុបណ្តាល វិធីក្នុងការស្តារបរិស្ថានអេកូឡូស៊ីឡើងវិញ ការខាតបង់នៃការស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ និងការខូចខាតនៃការបាត់បង់ជាបណ្តោះអាសន្ននៃមុខងារប្រព័ន្ធអេកូឡូស៊ី រវាងការខូចខាតនិងការស្តារប្រព័ន្ធអេកូឡូស៊ីជាក់ស្តែងនោះ តុលាការ គួរតែអនុម័ត
- ទស្សនៈយោបល់របស់អ្នកជំនាញ ដែលចែងនៅក្នុងបទប្បញ្ញត្តិពីមុន ដែលត្រូវបានសាកសួរឆ្លងហើយ អាចទទួលយកបានជាភស្តុតាង។

# វិធានទាក់ទងនឹងការសម្រេច



- កម្រិតជំនុំជម្រះទៅលើទីភ្នាក់ងារ

ការសម្រេចបឋម ត្រូវមានរបកគំហើញនៃអង្គហេតុ សេចក្តីសន្និដ្ឋានទាក់ទងនឹងបញ្ហាអង្គច្បាប់ឬធន្នានុសិទ្ធិ ទៅលើសម្ភារៈ ក៏ដូចជា មូលហេតុទៅលើបញ្ហាទាំងនោះ ហើយប្រសិនបើមានភាពសមស្រប ត្រូវមានការចេញជាអនុសាសន៍អំពី ការប៉ាន់ប្រមាណអំពីទណ្ឌកម្មផ្នែករដ្ឋប្បវេណី ដីកាអនុលោមភាព ដីកាសកម្មភាពកែតម្រូវ ឬវិធានការទៅលើលិខិតអនុញ្ញាតិ

- កម្រិតបណ្តឹងឧទ្ធរណ៍លើទីភ្នាក់ងារ

ក្រុមប្រឹក្សាតុលាការឧទ្ធរណ៍ផ្នែកបរិស្ថាន ត្រូវអនុម័ត កែសម្រួល ឬមិនពិចារណាទៅលើរបកគំនិតអង្គហេតុនិងសេចក្តីសន្និដ្ឋានទៅលើច្បាប់និងធន្នានុសិទ្ធិដែលមាននៅក្នុងការសម្រេចឬដីកាដែលកំពុងត្រូវបានពិនិត្យឡើងវិញនោះទេ និងត្រូវពន្យល់លម្អិតនៅក្នុងដីកាស្តាពរអំពីមូលហេតុសម្រាប់វិធានការទាំងនោះ។ ក្រុមប្រឹក្សាតុលាការឧទ្ធរណ៍ផ្នែកបរិស្ថាន អាចប៉ាន់ប្រមាណអំពីទោសប្បញ្ញត្តិ ដែលខ្ពស់ជាងឬទាបជាងកម្រិតដែលបានផ្តល់អនុសាសន៍ * * *។ ក្រុមប្រឹក្សាតុលាការឧទ្ធរណ៍ផ្នែកបរិស្ថាន អាចអនុម័ត កែសម្រួល ឬមិនពិចារណាទៅលើដីកាអនុលោម ដីកាកែតម្រូវ ឬវិធានការទៅលើលិខិតអនុញ្ញាតិដែលបានផ្តល់មកជាអនុសាសន៍។ ក្រុមប្រឹក្សាតុលាការឧទ្ធរណ៍ផ្នែកបរិស្ថាន  អាចបង្វិលសំណុំរឿងត្រឡប់ទៅប្រធានអង្គជំនុំជម្រះវិញ សម្រាប់ចាត់វិធានការបន្ថែមទៀត។

# វិធានទាក់ទងនឹងការសម្រេច (បន្ត)



- វិធានតុលាការសហព័ន្ធ
  - នៅពេលដែលសំណុំរឿងមួយត្រូវបានជំនុំជម្រះទៅលើអង្គហេតុ ដោយគ្មានគណៈវិនិច្ឆ័យទេ តុលាការត្រូវតែមានរបកគំហើញអំពីអង្គហេតុ និងបញ្ជាក់អំពីសេចក្តីសន្និដ្ឋានអង្គច្បាប់ ដាច់ដោយឡែក។
  - ពល់ដីកាដែលផ្តល់នូវការរក្សាការពារ និងពល់ដីកាដែលដាក់ការរឹតត្បិត ត្រូវបញ្ជាក់ជាពិសេស អំពីមូលហេតុដែលចេញដីកានេះ និងត្រូវរៀបរាប់លម្អិតឲ្យសមហេតុផល អំពីសកម្មភាពមួយឬច្រើនដែលត្រូវរឹតត្បិតឬដែលតម្រូវឲ្យធ្វើ។

# វិធានទាក់ទងនឹងការប្តឹងឧទ្ធរណ៍



- វិធានសម្រាប់ទីភ្នាក់ងារ
  - ក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីការចេញការសម្រេចបឋម ភាគីអាចប្តឹងឧទ្ធរណ៍បាន
  - សិទ្ធិរបស់ភាគីក្នុងការប្តឹងឧទ្ធរណ៍ ត្រូវកំណត់ត្រឹមបញ្ហាដែលបានលើកឡើងនៅក្នុងដំណើរការនីតិវិធី និងដោយការសម្រេចបឋម និងត្រឹមបញ្ហាដែលទាក់ទងនឹងយុត្តាធិការនៃកម្មវត្ថុ

# ដំណោះស្រាយ



## ឧទាហរណ៍ពី តុលាការកំពូលប្រទេសចិន

ទាក់ទងនឹងដំណោះស្រាយនិងការការអនុវត្តច្បាប់ក្នុងបណ្តឹងវិវាទផលប្រយោជន៍រដ្ឋប្បវេណីសាធារណៈទាក់ទងនឹងបរិស្ថាន (2015)

- តុលាការអាចតម្រូវឲ្យអ្នកបំពុល ស្តារបរិស្ថានឡើងវិញឲ្យដូចស្ថានភាពនិងមុខងារមុនពេលមានបង្កការខូចខាត។ ក្នុងករណីដែលការស្តារឡើងវិញទាំងស្រុង មិនអាចធ្វើទៅបានទេនោះ តុលាការអាចអនុញ្ញាតិឲ្យមានវិធីជំនួសក្នុងការស្តារឡើងវិញនេះ
- តុលាការដែលបានបញ្ជាឲ្យភាគីការពារក្តី ស្តារបរិស្ថានឡើងវិញនោះ អាចកំណត់អំពីតម្លៃនៃការស្តារឡើងវិញ នៅពេលដែលភាគីការពារក្តី ខកខានមិនបានអនុវត្តកាតព្វកិច្ចក្នុងការស្តារឡើងវិញនោះនៅពេលជំណាលគ្នា ឬចេញសាលក្រមដោយផ្ទាល់អំពីតម្លៃចំណាយក្នុងការស្តារបរិស្ថានប្រព័ន្ធអេកូឡូស៊ីឡើងវិញ ដែលជាបន្ទុករបស់ភាគីការពារក្តី។
- តម្លៃចំណាយក្នុងការស្តារបរិស្ថានប្រព័ន្ធអេកូឡូស៊ីឡើងវិញ រួមមានតម្លៃនៃការរៀបចំបង្កើតនិងអនុវត្តគម្រោងស្តារឡើងវិញ និងតម្លៃចំណាយក្នុងការចាត់ចែងការតាមដានគម្រោង។

# វិធានតុលាការ





កម្រិតនៃជោគជ័យរបស់យើង មានដែនកំណត់តែក្នុងការស្រមើស្រមៃរបស់យើងតែប៉ុណ្ណោះ ...

-- Aesop

# សកម្មភាពជាក្រុម



ធ្វើការក្នុងក្រុមតូចៗ។ សូមពិភាក្សាគំនិតដែលអ្នកមាន អំពីវិធាននីតិវិធីបរិស្ថានដែលមានប្រយោជន៍ក្នុងការដាក់ចូលទៅក្នុងតុលាការកម្ពុជា។

បន្ទាប់មក សូមឲ្យក្រុមនិមួយៗ រាយការណ៍អំពីគំនិតសំខាន់ៗដែលបានពិភាក្សា